# មេរៀនដំណាំស្ពៃខៀវ

## បច្ចេកទេសនៃការដាំដំណាំស្ពៃខៀវ

### ១.ការរៀបចំដី




☺ ជាដំបូងត្រូវភ្ជួរដីឬកាប់ដីហាលឱ្យបានរយៈពេលពី១០ថ្ងៃទៅ១៥ថ្ងៃ

☺ ត្រូវភ្ជួរប្រែដីឱ្យបាន២ទៅ៣ដងថែមទៀតក្នុងជម្រៅដីពី២តឹកទៅ៣តឹក។

### ២.ការលើករង




❖ យើងធ្វើរងទទឹងយកប្រវែង១ម៉ែត្ររីឯរងបណ្ដោយតាមលទ្ធភាព។

❖ លើកកំពស់រងពី២០ទៅ២៥សង់ទីម៉ែត្រសម្រាប់រដូវប្រាំង។

❖ លើកកំពស់រងពី២៥ទៅ៣០សង់ទីម៉ែត្រ សម្រាប់រដូវវស្សា។

## ៣.ការដាំដុះ



❖ ជាដំបូងយកគ្រាប់ពូជស្ពៃមកហាលថ្ងៃរយៈពេលពី៣០ទៅ៤០នាទី។

❖ បន្ទាប់មកត្រូវយកគ្រាប់ស្ពៃមកត្រាំទឹករយៈពេលពី៣ទៅ៥ម៉ោងរួចហើយផ្អាប់វារយៈពេល១យប់ដោយបិទគំរបឱ្យជិត។



❖ ត្រូវរៀបចំដីថ្នាលសម្រាប់សាបគ្រាប់ពូជឱ្យបានស្អាតល្អ។



❖ យកខ្សាច់៤ភាគមកច្របល់ជាមួយគ្រាប់ពូជស្ពៃឱ្យសព្វរួចហើយសាបឬព្រោះវានៅលើថ្នាលនោះឱ្យបានស្មើដៃល្អ។




❖ យកអំពុកចំបើង រោយទៅលើថ្នាល រួចហើយ ស្រោចទឹកពីលើវាភ្លាម។ បន្ថែមពីនោះ យើងអាចធ្វើ ដំបូលគ្របពីលើផងដែរ។



❖ នៅពេលកូនស្ពៃដុះ បានអាយុ១៥ថ្ងៃ ឬឃើញ មានចេញសន្លឹក៣ទៅ៤ សន្លឹក យើងអាចដកវាទៅ ស្ទូងបានហើយ។




❖ ត្រូវផ្អាកស្រោចទឹកកូនស្ពៃរយៈពេល១ថ្ងៃសិនមុនពេលដកវាទៅស្ទូង។



❖ នៅថ្ងៃបន្ទាប់ត្រូវស្រោចទឹកកូនស្ពៃរួចហើយដកវាភ្លាម។

❖ ពីគុម្ពមួយទៅគុម្ពមួយត្រូវទុកគម្លាតពីគ្នាប្រវែងពី១៥ទៅ២០សង់ទីម៉ែត្រ (ជាមធ្យម១៦ទៅ២០ដើមក្នុង១ម៉ែត្រការ៉េ)។




❖ ចន្លោះរងឬផ្លូវដើរអាចទុកប្រវែងពី៣០ទៅ៤០សង់ទីម៉ែត្រ (៣តឹកទៅ៤តឹក)។



## <u>របៀបម៉្យាងទៀត៖</u>



❖ <u>សម្រាប់ការព្រោះផ្ទាល់:</u> បន្ទាប់ពីផ្ទាប់គ្រាប់ពូជស្ពៃខៀវរួចមក ត្រូវយកវាទៅព្រោះនៅលើរងតែម្តង រួចហើយរោយអំពុកចំបើងពីលើ បន្ទាប់មកទៀតយើងត្រូវស្រោចទឹកវា៣ដងក្នុង១ថ្ងៃ បើស្ថានភាពដីមានសភាពស្ងួត។




❖ បើកូនស្ពៃដុះមកក្រាស់ពេក ត្រូវដកវាចេញខ្លះឬដកវាយកទៅស្ទូងនៅកន្លែងដែលទំនេរ។



## ៤.ការថែទាំ

- ក្រោយពីស្ទូងបានរយៈពេល១០ថ្ងៃ ត្រូវបោចស្មៅ ជ្រុំជើង និងដាក់ជីបំប៉ន (ជីធម្មជាតិ)។




- មើលសត្វល្អិតជាប្រចាំ។
- ស្រោចទឹកស្ពៃឱ្យបានគ្រប់គ្រាន់។




- បើឃើញកូនស្ពៃណា ចាប់ផ្ដើមពណ៌លឿងស្រពោន ត្រូវដកវាចេញហើយយកទៅចោលឱ្យឆ្ងាយ ឬកប់ដីក៏បាន។





# ៥.ការប្រមូលផល



➢ ផ្អាកស្រោចទឹករយៈពេល១ថ្ងៃ មុនពេលប្រមូលផលស្ពៃ។

➢ នៅពេលស្ពៃមានអាយុ៤៥ទៅ ៥០ថ្ងៃយើងអាចប្រមូលផលបានចំពោះស្ពៃសាបគ្រាប់ផ្ទាល់។



➢ នៅពេលស្ពៃខៀវអាយុ បានពី៥០ទៅ៦០ថ្ងៃ យើងអាច ប្រមូលផលបានចំពោះស្ពៃស្ទូង កូន។

➢ ទិន្នផលជាមធ្យម ទទួលបានពី១៦ទៅ១៨តោន សម្រាប់ផ្ទៃដីដាំ១ហិចតា៕



**សូមអរគុណ**

# មេរៀនដំណាំល្ពៅ

## បច្ចេកទេសនៃការដាំដំណាំល្ពៅ

### ១.ការជ្រើសរើសពូជ



- ពូជបង្កាត់: ជាពូជមានផ្លែច្រើន
- ពូជធម្មតា: ជាពូជអាចទុកដាំបន្តបាន
- ពូជដំណាំល្ពៅមានច្រើនប្រភេទដូចជាល្ពៅក្អែក ល្ពៅភ្នង ល្ពៅទ្រូឬល្ពៅហាប ។ល។



**១.ល្ពៅក្អែក:** វាជាល្ពៅដែលមានសំបកពណ៌ខ្មៅ ហើយផ្លែរបស់វារាងតូចមូល ចំណែកឯសាច់វាក្រាស់ ហើយមានពណ៌លឿងចាស់។ បន្ថែមពីនោះល្ពៅក្អែកមានគ្រាប់រាងមូលតូច។ ម៉្យាងវិញទៀតល្ពៅនេះត្រូវបានគេហៅថាល្ពៅភ្នំផងដែរ។ ពូជល្ពៅនេះវាធន់ទៅនឹងរដូវវស្សា។

**២.ល្ពៅភ្នង:** វាជាល្ពៅដែលមានសំបកពណ៌ប្រផេះមានផ្លែរាងតូច ទងធំ និងមានដើមតូច។ ពូជល្ពៅនេះត្រូវបានគេដាំនៅលើតំបន់ដីខ្ពង់ទាបឬដីទួល។



**៣.ល្ពៅទ្រូងឬល្ពៅចាប:** វាជាល្ពៅដែលមានស្លឹកធំ ដើមធំ និងទងវែង។ រីឯសាច់របស់វាមានពណ៌លឿងនិងមានជាតិសសៃរច្រើន។ ពូជល្ពៅនេះត្រូវបានគេដាំនៅតំបន់ដីទំនាប។



## ២.ការរៀបចំដី



☺ ភ្ជួរដីឬកាប់ដីហាលរយៈពេលពី១០ទៅ១៥ថ្ងៃ។

☺ បន្ទាប់មកត្រូវភ្ជួររាស់ដីឱ្យបាន២ទៅ៣ដងទៀតរួចរាស់បំបែកដីឱ្យបានម៉ដ្ឋល្អ។

## ៣.ការរៀបចំរងឬរណ្តៅ

❖ ការលើករងទទឹងគេអាចធ្វើបានចាប់ពី២ទៅ៣ម៉ែត្រដោយភ្ជួរពូនតែម្តង រីឯបណ្តោយរងតាមលទ្ធភាពដី។

❖ កំពស់រងអាចលើកចាប់ពី១៥ទៅ៣០សង់ទីម៉ែត្រដោយទៅតាមរដូវកាលផងដែរ។



❖ ជាទូទៅដំណាំល្ពៅគេកាប់រណ្តៅដាំ។

❖ នៅពេលវាដុះហើយទើបគេពូនរងតែម្តង។





## ៤.ការដាំដុះ

📖 ជាដំបូងត្រូវលាងសំអាតគ្រាប់ពូជាមុនសិន រួចយកវាទៅហាលថ្ងៃរយៈពេល៣ម៉ោង។





៣ ម៉ោង

🕮 យកគ្រាប់ពូជមកខ្ចប់នឹងក្រណាត់ ហើយយកវាទៅត្រាំទឹករយៈពេលពី៤ទៅ៥ម៉ោង រួចផ្អាប់រយៈពេល១យប់។




🕮 កាប់រណ្ដៅទំហំពី២ទៅ៣តឹក ក្នុងជម្រៅពី២ទៅ៣តឹកដែរ។




🕮 គម្លាតរណ្ដៅពីគុម្ពមួយទៅគុម្ពមួយ អាចទុកប្រវែងពី១២០សង់ទីម៉ែត្រទៅ១៥០សង់ទីម៉ែត្រ។



📖 ទ្រូងដំណាំល្ពៅ (ផ្លូវដើរ) អាចទុកចន្លោះចាប់ពី២ទៅ៣ម៉ែត្រ។




📖 ត្រូវដាក់ជីធម្មជាតិឬជីកំប៉ុស្ដិ៍សម្រាប់ទ្រាប់បាតរណ្ដៅផង

📖 ដាក់គ្រាប់ដាំចំនួន៣ទៅ៤គ្រាប់សម្រាប់១រណ្ដៅដោយកប់ជម្រៅ៣សង់ទីម៉ែត្រ។

📖 ក្នុងផ្ទៃដី១ហិចតាគេដាំចំនួន៤៥៦៥រណ្ដៅស្មើនឹងចំនួនគ្រាប់៤,៥គីឡូក្រាម។




## ៥.ការជ្រោយដី



📖 ការជ្រោយដី ពូនគល់ បោចស្មៅ គឺត្រូវធ្វើឡើងក្រោយពីដាំដុះបានរយៈពេលពី១៥ទៅ២០ថ្ងៃ។



- ត្រូវពិនិត្យនិងដករំលោះកូនចោលខ្លះ បើមានកូនច្រើនពេក។

## ៦.ការថែទាំ

- ត្រូវពិនិត្យមើលសត្វល្អិត ឬជម្ងឺផ្សេងៗ។





- ត្រូវស្រោចទឹកដំណាំល្ពៅឱ្យបានគ្រប់គ្រាន់ចាប់ពីពេលដាំរហូតដល់ពេលប្រមូលផល។





## ៧.ការប្រមូលផល



➤ ការប្រមូលផលវាអាស្រ័យទៅលើពូជ ពូជខ្លះចាប់ពីអាយុ៨០ទៅ៨៥ថ្ងៃ ពូជខ្លះទៀតចាប់ពីអាយុ៩៥ទៅ ១១០ថ្ងៃ។



➤ យើងត្រូវពិនិត្យមើលទៅលើតម្រូវការនៃទីផ្សារ។

## ៨.ការរក្សាពូជ



✓ យើងអាចរក្សាពូជល្ពៅទុកដាំបន្តបានលុះត្រាតែពូជនោះមិនមែនជាពូជបង្កាត់។

✓ ត្រូវពិនិត្យយកផ្លែណាដែលទុំល្អ ហើយមិនមានស្នាមសត្វចោះ។

✓ ទុកផ្លែល្ពៅឱ្យទុំញោ រួច ទើបពុះយកគ្រាប់ បន្ទាប់មក លាងទឹកវាឱ្យស្អាតល្អ។





✓ យកគ្រាប់ដែលលាងទឹករួចនោះយកទៅ





ហាលថ្ងៃឱ្យស្ងួត រួចហើយច្រកដាក់ក្នុងដប ក្នុងកែវ ឬខ្ចប់នឹងក្រណាត់រក្សាទុកឱ្យបានល្អ៕





**សូមអរគុណ**

# មេរៀនដំណាំសណ្តែកកួរ (សណ្តែកទ្រើង)

## ១.សេចក្តីផ្តើម





សណ្តែកទ្រើងគឺជាដំណាំឬជាបន្លែដែលកសិករនិយមដាំ និងនិយមបរិភោគពីព្រោះវាមានរសជាតិឆ្ងាញ់និងសម្បូរទៅដោយជីវជាតិសម្រាប់ទ្រទ្រង់សរីរាង្គកាយមានដូចជា ជាតិទឹក ប្រូតេអ៊ីន ខ្លាញ់ កាបូនអ៊ីត្រាត និងកាលស្យូម។

## ២.ការជ្រើសរើសពូជ

ការជ្រើសរើសពូជជាកត្តាសំខាន់ដំបូងសំរាប់ការដាំដុះកំណត់ទិន្នផលនិងតម្រូវការទីផ្សារ។ កត្តាសំខាន់ៗដែលត្រូវកំណត់ជ្រើសរើសមានដូចជា៖





១.ពូជសុទ្ធល្អ

២.ពូជមានប្រភពច្បាស់លាស់(ពូជក្នុងស្រុកឬពូជបង្កាត់)

៣.ពូជមានអាយុកាលត្រឹមត្រូវ




៤.ពូជដុះល្អពី៨៥-៩០%

៥.ពូជធន់នឹងអាកាសធាតុ ធន់នឹងសត្វល្អិត និងធន់នឹងជម្ងឺ

៦.ចំពោះពូជបង្កាត់មិនអាចទុកពូជសម្រាប់ដាំបន្តបានទេ។

# ៣.បច្ចេកទេសដាំដុះ

## ៣.១ ការរៀបចំដី






១)កាប់ឬភ្ជួរដីហាលរយៈពេលពី១០ទៅ១៥ថ្ងៃបន្ទាប់មកភ្ជួរប្រែវា២ទៅ៣ដងទៀត

២)កាប់ដីឬភ្ជួរដីឲ្យបានជម្រៅពី២០ទៅ២៥សង់ទីម៉ែត្ររួចវាយបំបែកដីឲ្យម៉ដ្ឋ ព្រមទាំងរើសយកស្មៅចេញឲ្យស្អាតផង។

## ៣.២ ការលើករង




១)ធ្វើរងទទឹងប្រវែង០,៨ម៉ែត្រទៅ១ម៉ែត្រ បណ្តោយតាមលទ្ធភាព។

២)កំពស់រងនៅរដូវប្រាំងពី១៥សង់ទីម៉ែត្រទៅ២០សង់ទីម៉ែត្រ

៣)កំពស់រងនៅរដូវវស្សាពី២សង់ទីម៉ែត្រទៅ៣០សង់ទីម៉ែត្រ។



៤)ពីរងមួយទៅរងមួយត្រូវទុកគម្លាតពីគ្នាប្រវែង ៣០សង់ទីម៉ែត្រ។




៥)ដាក់ជីកំប៉ុស្តិ៍ទំងន់០,៥គីឡូក្រាមទៅ១គីឡូក្រាមសម្រាប់ក្នុងមួយរណ្តៅ ហើយច្របល់វាឱ្យសព្វ  រួចហើយកៀររាស់វាឲ្យបានស្មើល្អ។




៦)ជីករណ្តៅក្នុងជម្រៅពី១៥សង់ទីម៉ែត្រទៅ២០សង់ទីម៉ែត្រ ជាពីរជួរដែលមានចន្លោះគុម្ពពី ៤០ស.មទៅ៥០សង់ទីម៉ែត្រ និងចន្លោះជួពី៦០សង់ទីម៉ែត្រ ទៅ៧០សង់ទីម៉ែត្រ។



# ៣.៣ របៀបដាំដុះ

## ក-ការដាំគ្រាប់ដោយផ្ទាល់




- យកគ្រាប់ពូជសណ្តែកគួរទៅហាលថ្ងៃរយៈពេលពី១ទៅ២ម៉ោងរួចយកវាទៅត្រាំទឹកស្អាតរយៈពេលពី៣ទៅ៤ម៉ោង។

- បន្ទាប់មកត្រូវផ្អាប់គ្រាប់ពូជរយៈពេល១យប់ដើម្បីឲ្យវាឆាប់ដុះពន្លក។




- ដាក់ជីកំប៉ុស្តិ៍ដែលរលួយល្អចំនួន 0,៥គីឡូក្រាមក្នុង១រណ្តៅ។




- ដាក់គ្រាប់ពូជសណ្តែកគួរដាំក្នុង១រណ្តៅចំនួន២គ្រាប់ទៅ៣គ្រាប់កប់ដីក្នុងជម្រៅ៣សង់ទីម៉ែត្រ។

❖ រោយដីដែលមានជីជាតិនិងកំទេចចំបើងស្ងួតបន្តិចពីលើរណ្តៅរួចស្រោចទឹកឲ្យបានជោគល្អស្រោចវាព្រឹកល្ងាច។




❖ ក្រោយពីដាំបាន១៥ថ្ងៃត្រូវដកកូនរំលួស(ធីវកូន)មើលដើមណាដែលអន់ត្រូវដកចេញទុកតែដើមណាដែលល្អពី២ទៅ៣ដើមក្នុង១គុម្ពបានហើយ។



## ៨-ការបណ្ដុះកូន

គេបណ្ដុះកូនសណ្ដែកទ្រើងដោយប្រើថង់ប្លាស្ទិកឬកន្ទោងស្លឹកចេកដែលមានច្រកដីពេញដោយប្រើល្បាយរួមមាន៖





- ដីកំប៉ុស្ដិ៍ឬដីលាមកសត្វ៥០ភាគរយ
- ដីដំបូកឬដីមានជីជាតិ២៥%
- ដីខ្សាច់ម៉ដ្ដល្អ២៥%



- ដាក់គ្រាប់សណ្ដែកក្នុងថង់ឬកន្ទោងចំនួន១ទៅ២គ្រាប់រួចស្រោចទឹកឲ្យជោគ (បាតថង់ឬកន្ទោងត្រូវជ្រាបទឹកបានល្អ)។
- ក្រោយពីបណ្ដុះបានពី៦ទៅ៧ថ្ងៃឬកូនសណ្ដែកមានស្លឹកកំណើតពី២ទៅ៣សន្លឹកអាចយកវាទៅដាំបាន។



## គ-ការដាំកូន




🕮 ជីករណ្ដៅជាពីរជួរដែលមានចន្លោះពីរណ្ដៅមួយទៅរណ្ដៅមួយទៀតគឺពី៤០សង់ទីម៉ែត្រទៅ៥០សង់ទីម៉ែត្រ និងចន្លោះជួរពី១ជួរទៅ១ជួរគឺ ពី៦០សង់ទីម៉ែត្រទៅ៧០សង់ទីម៉ែត្រ។



🕮 ដាក់កូនសណ្ដែកដាំ១ដើមទៅ២ដើមក្នុងមួយរណ្ដៅ។



🕮 ត្រូវយកកំទេចចំបើងខ្លីៗមកគ្របគល់សណ្ដែកបន្ទាប់ពីដាំរួច ដើម្បីការពារសំណើមបន្ទាប់មកស្រោចទឹកវាភ្លាមឲ្យបានជោគល្អ។

# ៤.ការថែទាំ

## ៤.១ ការកំចាត់ស្មៅជ្រោយដីនិងពូនរង




🕮 <u>លើកទី១</u>: ធ្វើវាបន្ទាប់ពីដាំបានរយៈពេលពី១០ទៅ១២ថ្ងៃ។

📖 **លើកទី២:** ធ្វើវាក្រោយពេលជ្រោយដី លើកទី១បាន ១៥ថ្ងៃ ឬ សណ្តែកអាយុបាន ២៥ថ្ងៃ។




📖 **លើកទី៣:** ធ្វើវានៅពេលសណ្តែកអាយុបាន៤០ថ្ងៃ គឺគ្រាន់តែកាត់ស្មៅត្រឹមដីឬដកស្មៅទាំងឫសមិនចាំបាច់ជ្រោយគល់ទៀតទេ។




## ៤.២ ការដាក់ជី

ការប្រើប្រាស់ជីទ្រាប់បាតគឺដាក់ជីកំប៉ុស្តិ៍ចំនួនកន្លះគីឡូក្រាមទៅ ១គីឡូក្រាមក្នុង១រណ្តៅ ដោយលាយច្របល់ឱ្យសព្វជាមួយដីនៅក្នុងរណ្តៅនោះ។



## ៤.៣ ការដោតចំណារឬទ្រើងនិងការកាត់មែក




- យកកូនឈើនិងឫស្សីប្រវែងពី២ម៉ែត្រទៅ២,៥ម៉ែត្រមកធ្វើចំណារ។
- ដោតចំណារប្រឈមមុខគ្នានៅពេលកូនសណ្តែកលូតលាស់បានពី៤ទៅ៥សន្លឹក ដែលមានកំពស់ពី១៥សង់ទីម៉ែត្រទៅ២០សង់ទីម៉ែត្រ។



- ក្រោយពេលដាំបាន២០ទៅ២៥ថ្ងៃឬពេលសណ្តែកបែកខ្នែងត្រូវរុំខ្នែង នឹងដើមរបស់វាឬរុំជាប់ទៅនឹងចំណារក៏បាន។





- ត្រូវកាត់សំអាតមែកតូចៗចេញទុកតែមែកចំបងដោយធ្វើវានៅពេលសណ្តែកមានអាយុ២០ទៅ២៥ថ្ងៃ។
- កាត់ស្លឹកចាស់ៗដែលកើតជម្ងឺចោល ដើម្បីកាត់បន្ថយការឆ្លងជម្ងឺ និងកាត់បន្ថយជម្រកសត្វល្អិតហើយវាក៏អាចស្រូបយកជីវជាតិពីដីបានផងដែរ។

## ៤.៤ ការស្រោចទឹក

- សណ្តែកកួរត្រូវការទឹកជាប្រចាំតែមិនត្រូវការដក់ទឹកនៅក្នុងរងឬក្នុងចំការទេ

- យើងត្រូវស្រោចទឹក២ដងក្នុង១ថ្ងៃ នៅពេលព្រឹកនិងពេលល្ងាច។



ស្រោចទឹក២ដងក្នុង១ថ្ងៃ

- ចំពោះការបញ្ចូលទឹកត្រូវបញ្ចូល២ដងក្នុង១សប្តាហ៍ដោយយោងទៅតាមសភាពដី និងអាកាសធាតុ។



- ត្រូវត្រួតពិនិត្យដីថាតើមានសំណើមគ្រប់គ្រាន់ឬទេ ជាពិសេសនៅពេលសណ្តែកចាប់ផ្តើមចេញផ្កា(អាយុ៣០ថ្ងៃ) រហូតដល់ពេលប្រមូលផល។





# ៥.ការប្រមូលផល

❖ យើងអាចប្រមូលផលបាននៅពេលសណ្តែកមានអាយុចាប់ពី៦០ថ្ងៃទៅ៧៥ថ្ងៃ ដោយចាប់គិតពីពេលដាំ និងទៅតាមប្រភេទពូជផងដែរ។




❖ ការប្រមូលផលគឺត្រូវធ្វើឡើងនៅពេលរសៀល ហើយយើងអាចប្រមូលផលពី ១៥ទៅ១៨ដងនៅក្នុងរដូវដាំសណ្តែកកួរ។

❖ គេមិនត្រូវក្តិចក្រោមទងស្នែងឬសន្ទង់ទេ (លើសាច់សណ្តែកកួរ) ព្រោះធ្វើឲ្យសណ្តែករក្សាទុកមិនបានយូរឬឆាប់ហើមនិងមិនគួរកាត់ទាំងទងស្នែងឬសន្ទង់ទេព្រោះធ្វើឲ្យទងស្នែងឬសន្ទង់នោះលែងចេញផ្កាតទៅទៀត។



❖ បេះផ្លែថ្មីៗ ដាក់ក្រោមម្លប់ ព្រោះវាអាចធ្វើឱ្យបែកញើសហើយក្លាយទៅជាពណ៌លឿងនាំឲ្យឆាប់ខូច។



# ៦.ការរក្សាពូជទុក

➢ ហាមទុកពូជចំពោះផ្លែណាដែលនៅក្បែរដី តែត្រូវទុកពូជចំពោះផ្លែណាដែលនៅខ្ពស់ផុតពីដី កួរវែងល្អគ្មានជម្ងឺ និងគ្មានការបំផ្លាញពីពពួកសត្វល្អិតចង្រៃផ្សេងៗ។



➢ រើសយកកួរសណ្តែកដែលផ្លែសារទី២ទៅ៤នៃដើមនិងជ្រើសយក២ទៅ៣កួរប៉ុណ្ណោះក្នុង១ដើមទុកវាឲ្យទុំស្ងួតនៅលើដើមទើបយើងបេះវាមកហាលថ្ងៃឲ្យស្ងួតល្អ។



➢ ញីបំបែកវាដើម្បីយកគ្រាប់ចេញ ហើយយកគ្រាប់នោះមកហាលថ្ងៃឲ្យស្ងួតម្តងទៀតរយៈពេលពី២ទៅ៣ថ្ងៃអត្រាសំណើមពី១២ទៅ១៣ភាគរយ។



- ប្រេកគ្រាប់ពូជទាំងនោះចូលក្នុងដប(ទុក១ភាគ៣នៃដប) ឬក្នុងថង់ក្រណាត់ ហើយចងឬបិទឲ្យជិតរួចរក្សាទុក នៅកន្លែងមានសុវត្ថិភាពនិងមាន ខ្យល់ចេញចូលគ្រប់គ្រាន់។



- រយៈពេលពី៣ឬ៤ខែត្រូវបញ្ចេញហាលថ្ងៃម្តង  គឺរយៈពេលពី២ទៅ៣ម៉ោង ធ្វើឲ្យគ្រាប់ពូជមានសុខភាពល្អរក្សាដំណុះ បានយូរក្នុងករណីគ្រាប់នោះស្ងួតបានល្អ អត្រាសំណើមពី១២ទៅ១៣ភាគរយ៕



ហាល២ម៉ោង ➡ ៣ម៉ោងសម្រាប់៣ខែម្តង

## សូមអរគុណ

# ការចូលរួមនិងកិច្ចសហប្រតិបត្តិការ

## អ្នករៀបចំដើម្បីបង្កើតនិងកែសម្រួលសៀវភៅហត្ថកម្ម

❖ **លោក ឆួន សាលី** នាយកប្រតិបត្តិរបស់អង្គការអភិវឌ្ឍន៍សហគមន៍ កសិកម្មបែបធម្មជាតិនិង រក្សាបរិស្ថានជនបទ ហៅកាត់ថា ស៊ី អារ៍ ឌី ណាស់។

❖ **លោក យុក សឿន** នាយករង របស់អង្គការអភិវឌ្ឍន៍សហគមន៍ កសិកម្មបែបធម្មជាតិនិង រក្សាបរិស្ថានជនបទ ហៅកាត់ថា ស៊ី អារ៍ ឌី ណាស់។

❖ **លោកស្រី ស៊ុន សុគន្ធី** មន្ត្រីគម្រោង របស់អង្គការអភិវឌ្ឍន៍សហគមន៍ កសិកម្មបែបធម្មជាតិនិង រក្សាបរិស្ថានជនបទ ហៅកាត់ថា ស៊ី អារ៍ ឌី ណាស់។

## រូបថតសម្រាប់សៀវភៅនេះត្រូវបានសហការនិងជួយគាំទ្រដោយ

❖ គ្រួសារជនពិការដែលរស់នៅក្នុងភូមិដូចខាងក្រោម៖

- គ្រួសារ**លោក គីន ជេម** និងគ្រួសារ**លោក ម៉ា សៀវម៉ុន** នៅភូមិតាសែន
- គ្រួសារ**លោក ពិរុដ សារឿន** នៅភូមិស្វាយព្រៃ
- **លោក ស៊ុន សន** នៅភូមិស្វាយ
- គ្រួសារ**អ្នកស្រី ហោ លេខ**, **លោក ម៉េ សំណាង** និង **លោក សេខ សាម៉េត** នៅភូមិអូរអន្លក់
- គ្រួសារ**លោក ឃួន ឆិល** នៅភូមិ អូរជា
- **លោក ឌិល សាមិត** នៅភូមិកណ្តាល

- គ្រួសារ**លោក ទិល ឡៃន** នៅភូមិកំរៀង
- គ្រួសារ**លោក ឯម ម៉ុខ** នៅភូមិស្រែឡៅទង
- គ្រួសារ**លោក លាន ចាន់ណា** នៅភូមិរកាបុស្ស

❖ អ្នកភូមិដែលទទួលផលពីអង្គការ ធារ៉ា រីនេសសាន់៖

- **លោក អ៊ួច សារឿត** នៅភូមិរកាបុស្ស និង
- **អ្នកស្រី ចឹក ហេង** នៅភូមិរកាបុស្ស

❖ បុគ្គលិករបស់ អង្គការ ធារ៉ា រីនេសសាន់៖

- **លោកស្រី យ៉ត យ៉េត**
- **លោកស្រី សំរិទ្ធិ សារ៉ាច** និង
- **លោក ខៃ សារ៉ែន**

# ឯកសារយោង

📖 មេរៀនដំណាំ**<u>បន្លែស្លែខៀវ</u>** និង**<u>បន្លែសណ្តែកកួរ</u>** ត្រូវបានដកស្រង់ចេញពី **<u>សៀវភៅបច្ចេកទេសដាំបន្លែជាលក្ខណៈគ្រួសារ</u>** *(រៀបចំដោយនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំនិងកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំជាតិនៃអគ្គនាយកដ្ឋានកសិកម្ម ក្នុងខែសីហា ឆ្នាំ២០១៣)* និងដកស្រង់ចេញពី **<u>វិបសាយ</u>**: <u>www.tssdcambodia.org</u>

📖 មេរៀន**<u>ដំណាំល្ពៅ</u>**ត្រូវបានដកស្រង់ចេញពី**<u>មណ្ឌលពត៌មាននិងឯកសារកសិកម្ម</u>** *(ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)*៕